**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..៤៦..សសរ...

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសិក្សា និងរៀបចំបង្កើត និងដំឡើងកម្រិតច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារព្រំដែនសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់



www.pheakdeylaw.com

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសិក្សា និងរៀបចំបង្កើត និងដំឡើងកម្រិតច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្តម **ង៉ាំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | អនុប្រធាន |
| ៣.តំណាងគណៈកម្មាធិការចំពុះកិច្ចការព្រំដែន | | អនុប្រធាន |
| ៤. ឯកឧត្តម **សេង ទី** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិកអចិន្ត្រៃយ៍ |
| ៥. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | | សមាជិក |
| ៦. តំណាងក្រសួងការពារជាតិ | | សមាជិក |
| ៧. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |
| ៨. តំណាងក្រសួងពាណិជ្ជកម្ម | | សមាជិក |
| ៩. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | សមាជិក |
| ១០.តំណាងក្រសួងសុខាភិបាល | | សមាជិក |
| ១១.ឯកឧត្តម **ប្រាក់ សំអឿន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១២.ឯកឧត្តម នាយឧត្តមសេនីយ៍ **សុខ ផល** | អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ១៣. ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ | | សមាជិក |
| ១៤.ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង | | សមាជិក |
| ១៥.ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង | | សមាជិក |
| ១៦.ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល | | សមាជិក |
| ១៧.ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តក្រចេះ | | សមាជិក |
| ១៨.ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តតាកែវ | | សមាជិក |
| ១៩.ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី | | សមាជិក |
| ២០.ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តរតនគិរី | | សមាជិក |
| ២១.ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តកំពត | | សមាជិក |
| ២២.ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តកែប | | សមាជិក |



៥

www.pheakdeylaw.com

២៣. ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ សមាជិក

២៤. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ហ៊ុ សាគុណ** អគ្គស្នងការរងនគរបាលជាតិ សមាជិក

២៥. តំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សមាជិក

២៦. តំណាងអគ្គនាយកដ្ឋានកាំកុងត្រូល សមាជិក

២៧. ឯកឧត្តម **សួស ច្រាដ្ឋា** អគ្គនាយករងទទួលបន្ទុកជាប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត នៃក្រសួងមហាផ្ទៃ សមាជិក

២៨. ឯកឧត្តម **ហួត ស៊ីនាដ** អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ សមាជិក

**ប្រការ ២.-**

ក្រុមការងារអន្តរក្រសួងនេះមានតួនាទី ភារកិច្ចដូចខាងក្រោម៖

- សិក្សា និងរៀបចំផែនការសម្រាប់ការបង្កើត និងដំឡើងកម្រិតច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម
- ពិនិត្យ និងវាយតម្លៃក្នុងការបង្កើត និងដំឡើងកម្រិតច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម
- សម្របសម្រួលជាមួយក្រុមការងារអន្តរក្រសួងរបស់ភាគីវៀតណាមដើម្បីសិក្សា រៀបចំបង្កើត និងដំឡើងកម្រិតច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម
- សិក្សា និងរៀបចំបទដ្ឋានគតិយុត្តដើម្បីជួយគាំទ្រដល់ការបង្កើត និងដំឡើងកម្រិតច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម
- រៀបចំសំណុំបែបបទ និងនីតិវិធីក្នុងការបង្កើត និងដំឡើងកម្រិតច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម
- ពិគ្រោះពិភាក្សាជាមួយភាគីវៀតណាមក្នុងការបង្កើត និងដំឡើងកម្រិតច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម
- ពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានាក្នុងការបង្កើត និងដំឡើងកម្រិតច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម
- លើកគម្រោងកែលម្អ និងសាងសង់អគារទីស្នាក់ការត្រួតពិនិត្យ និងហេដ្ឋារចនាសម្ព័ន្ធនានានៅតាមច្រកទ្វារព្រំដែនកម្ពុជា-វៀតណាមឲ្យបានសមស្រប
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនក្រសួងមហាផ្ទៃ និងប្រមុខរាជរដ្ឋាភិបាលកម្ពុជា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ ៣.-**

ក្នុងការអនុវត្តការងារ ប្រធានក្រុមការងារអន្តរក្រសួងត្រូវរាយការណ៍ និងសុំយោបល់ដឹកនាំដោយផ្ទាល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិកក្រុមការងារអន្តរក្រសួង ត្រូវបំពេញការងារតាមការបាត់ចែងរបស់ប្រធានក្រុមការងារអន្តរក្រសួង។



www.pheakdeylaw.com

**ប្រការ ៤.-**

ក្រុមការងារអន្តរក្រសួងមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ឲ្យចូលរួមកិច្ចប្រជុំ ឬចូលរួមក្នុងកិច្ចការណាមួយតាមការចាំបាច់។

ក្រុមការងារអន្តរក្រសួងមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ខ្លួន ដើម្បីជួយការងារតាមតម្រូវការចាំបាច់។

**ប្រការ ៥.-**

ក្រុមការងារអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ក្នុងការចាត់ចែងការងាររបស់ខ្លួន។

**ប្រការ ៦.-**

ការចំណាយផ្សេងៗនៅក្នុងការបំពេញការងាររបស់ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារអន្តរក្រសួង ត្រូវប្រើប្រាស់ថវិការបស់ក្រសួង ស្ថាប័នសាមី។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តជាប់ព្រំដែនជាមួយប្រទេសវៀតណាម និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល៖**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com